## Calming someone down



### ភ័យ

លីដា៖ សុគន្ធ ម៉េចហ្នឹង? មើលទៅដូចភ័យម៉េះ? មានរឿងអីអ៎?

សុគន្ធ៖ ខ្ញុំទើបនឹកឃើញ ម្សិលមិញ ខ្ញុំដូចច្រឡំផ្ញើឯកសារទៅក្រុមហ៊ុនខុស ... តិចមានបញ្ហាអីទៅ បង?

លីដា៖ កុំអាលភ័យ។ ចាំទៅដល់ក្រុមហ៊ុន ពិនិត្យមើលឲ្យច្បាស់សិនមើល។ ទោះជាផ្ញើខុស បើឯកសារមិនសូវសំខាន់ ក៏អត់មានបញ្ហាអីដែរ។

សុគន្ធ៖ អីចឹងអ៎បង? ប៉ុន្តែ បើមេដឹង ខ្ញុំច្បាស់ជាត្រូវមាត់ហើយ។

លីដា៖ ត្រូវមាត់ ត្រូវទៅ។ ខុសតិចតួច មានអី។ អ្នកណាដែលមិនដែលធ្វើខុស? មានតែអ្នកអត់ធ្វើ បានអត់ដែលខុស។

### ប្រញាប់ប្រញាល់

ប្អូន៖ យឺតហើយៗ ទៅប្រឡងអត់ទាន់អេ៎ ... ធ្វើម៉េចទៅ?

បង៖ យប់មិញនៅដល់យប់ពេកហ្នឹងអា៎។ ថាឲ្យចូលដេកលឿនតិច អត់។ ឥឡូវ រហន់ៗ។

ប្អូន៖ ចុះបើត្រូវមើលមេរៀន ...

បង៖ ម៉ោ ចាំបងជិះម៉ូតូជូនទៅ។ កន្លះម៉ោងប្រហែលជាទាន់ហើយ។

| | |
|---|---|
| លីដា / សុគន្ធ | female / male Cambodian names |
| ម៉េះ | spoken form of ម្ល៉េះ = thus, so, in this way, this much |
| អ៎ | particle used to form a yes/no question, similar to ឬ |
| តិច ... | [phrase-initial] it is possible that ... (expressing concern) |
| កុំអាល ... | don’t ..., don’t rush to ... |
| មេ | boss |
| ត្រូវមាត់ | to be scolded, to be reprimanded |
| ត្រូវមាត់ ត្រូវទៅ | *something like:* even if you are scolded, let it happen |
| មានអី | no problem |
| អេ៎ | spoken form of the question or negation particle ទេ |
| អា៎ | emphatic particle |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ថាឲ្យ + verb | I told you to [do sth.] |
| អត់ | *here:* you didn't do it / you didn't listen to me |
| រហាន់ៗ | (colloquial use) to be in a rush |
| ចុះបើត្រូវមើលមេរៀន ... | What if I had to study/review my lessons ...? |
| ម៉ោ | spoken form of មក = to come |
| ចាំបងជិះម៉ូតូជូនទៅ | I'll give you a lift (with a motorcycle) |

## Cultural notes

"គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ" ជាពាក្យស្លោកដែលខ្មែរប្រើញឹកញាប់សំដៅលើអ្នកដែលកំពុងលាក់បាំងនូវអ្វីដែលខ្លួនបានធ្វើខុស (គោ) ហើយខ្លាចគេចាប់កំហុសខ្លួនបាន (ដំបៅ) ដូច្នេះឆាប់ភ័យឬងាយប្រតិកម្ម (រំសាយកន្ទុយ) ទៅនឹងសំដីឬអាកប្បកិរិយារបស់អ្នកដទៃ (ក្អែក)។

| | |
|---|---|
| ដំបៅ | wound |
| ក្អែក | crow |
| ហើររំលង | to fly past |
| ពាក្យស្លោក | saying |
| លាក់បាំង | to conceal, to hide |
| ប្រតិកម្ម | to react; reaction |
| សំដី | words, speech, utterance |
| អាកប្បកិរិយា | attitude, behaviour, conduct |

## Additional dialogue

លីដា៖ សុគន្ធ ប្រញាប់ទៅណាហ្នឹង? ស្លន់ស្លោម៉េះ?

សុគន្ធ៖ ខ្ញុំត្រូវទៅជួបគេបង។ យឺតម៉ោងហើយ ឥឡូវកុំព្យូទ័រគាំងទៀត។ យ៉ាប់ម៉ង។

លីដា៖ តែបិទតាសអី? ចាំបងជួយបិទកុំព្យូទ័រឲ្យក៏បាន។ បើមើលទៅយឺតហើយ តេប្រាប់គេតិចទៅ គេមិនខឹងអីទេ។

សុគន្ធ៖ បាទបង អរគុណ។ អីចឹងបងជួយបិទកុំព្យូទ័រឲ្យខ្ញុំផងណា។ ខ្ញុំទៅហើយ។

| | |
|---|---|
| ស្លន់ស្លោ | to hurry, to rush, to panic |
| គាំង | to get stuck, to freeze |
| យ៉ាប់ម៉ង | this is really bad/annoying |
| តេ | to call, to phone |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.